# រាជបណ្ឌិត្យសភាកម្ពុជា

## លទ្ធផលកិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ
## នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នៅខែឧសភា ឆ្នាំ២០១៨

( ចងក្រងដោយ៖ RAC Media; ប្រភពឯកសារ៖ កជភខ )

### ១-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៨

ថ្ងៃពុធ ៣រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពរបស់ ឯកឧត្តមបណ្ឌិត ហ៊ាន សុខុម ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ បានបន្តប្រជុំ ពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច បានចំនួន០២ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- សេវាធនាគារចល័ត/ ធនាគារកិច្ចចល័ត<br>អ. mobile banking<br>បារ. service bancaire mobile (m.) | សេវាផ្ដល់ដោយធនាគារឬគ្រឹះស្ថានហិរញ្ញវត្ថុដែលអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុពីចម្ងាយដោយប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចចល័ត ដូចជា ទូរសព្ទដៃ កុំព្យូទ័រ ជាដើម និងដោយប្រើកម្មវិធី របស់ធនាគារឬគ្រឹះស្ថានហិរញ្ញវត្ថុនោះ។ |
| ២- បេឡាធិការ<br>អ. cashier<br>បារ. caissier (m.) | អ្នកទទួលខុសត្រូវប្រតិបត្តិការទទួលប្រាក់និងបញ្ចេញប្រាក់នៅក្នុងស្ថាប័នរដ្ឋ ក្រុមហ៊ុនឯកជនជាដើម។ |

### ២-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨

ថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ហ៊ាន សុខុម ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ បានដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សា និងអនុម័ត ទៅលើបច្ចេកសព្ទមួយចំនួន ដែលស្នើដោយរាជបណ្ឌិត្យសភាកម្ពុជា។ កិច្ចប្រជុំបានពិភាក្សាយ៉ាងផុសផុលទៅលើបច្ចេកសព្ទទាំងអស់នោះ ជាលទ្ធផលសម្រាប់កិច្ចប្រជុំថ្ងៃនេះ ក្រុមប្រឹក្សាជាតិភាសាខ្មែរ បានអនុម័តបានចំនួន០១ពាក្យ ដូចខាងក្រោម៖

| |
|---|
| គោរមវន្ត<br>អ. title awardee/ laureate<br>បារ. lauréat |

## ៣-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨

ថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពរបស់ ឯកឧត្តមបណ្ឌិត ហ៊ាន សុខុម ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ បានដឹកនាំអង្គប្រជុំពិនិត្យ ពិភាក្សា និងអនុម័តទៅលើបច្ចេកសព្ទមួយចំនួនដែលស្នើដោយរាជបណ្ឌិត្យសភាកម្ពុជា បានចំនួន១១ពាក្យ ដូចខាងក្រោម៖

១- គោរមងារ
អ. title
បារ. titre (m.)

២- គោរមងារវិទ្យាសាស្ត្រ
អ. scientific title
បារ. titre scientifique

៣- គោរមងារកិត្តិយស
អ. honorary title
បារ. titre honorifique

៤- អគ្គមហាបណ្ឌិតសភាចារទ្ទិសាបាមោក្ខ
ឡា. Akka Moha Binditsapheacha Tisapamok

៥- អគ្គបណ្ឌិតសភាចារ្យ
ឡា. Akka Binditsapheacha

៦- កិត្តិបរិរក្សបណ្ឌិត
ឡា. Kittiparirakbindit

៧- កិត្តិសេដ្ឋាបណ្ឌិត
ឡា. Kittisethabindit

៨- កិត្តិសង្គហបណ្ឌិត
ឡា. Kittisangkahabindit

៩- កិត្តិនីតិកោសលបណ្ឌិត
ឡា. Kittinitikosalbindit

១០- កិត្តិឧទ្ទេសបណ្ឌិត
ឡា. Kittiutesbindit

១១- កិត្តិបណ្ឌិត
ឡា. Kittibindit



## ៤-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨

ថ្ងៃអង្គារ ៨កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត ជួរ គារី បានបន្តប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការទស្សនវិជ្ជា បានចំនួន ០២ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| **១- បញ្ហាចិត្ត-កាយ**<br>អ. mind-body problem<br>បារ. | បញ្ហាទស្សនវិជ្ជាអំពីចិត្តដែលនិយាយអំពីទំនាក់ទំនងរវាងចិត្តនិងកាយ។<br>បញ្ញត្តិនេះត្រូវបានបង្កើតឡើងដំបូងដោយប្លាតុង(Platon/Plato)និងអារីស្តូត(Aristote/Aristotle) ហើយក្រោយមក ដេកាត(Descartes) បាន ចាត់ទុកបញ្ហាចិត្ត-កាយនេះជាបញ្ហាស្នូលក្នុងទស្សនវិជ្ជាទំនើប។ ដេកាតជឿ ថាចិត្តមានការគិតជាខ្លឹមរបស់វា ហើយចិត្តគឺជាអង្គដាច់ដោយឡែកពីរាងកាយ ឬជាសារធាតុបន្ថែម។<br>មានទស្សនៈពីរដែលនិយាយពីបញ្ហាចិត្ត-កាយ គឺឯកនិយម(monism) និងទ្វិកនិយម(dualism)។<br>ឯកនិយម(monism) អះអាងថា មនុស្សត្រូវបានបង្កើតពីរូបធាតុឬកាយ ហើយអ្វីៗដែលលេចចេញពីកាយ គឺគ្រាន់តែមុខងាររបស់កាយប៉ុណ្ណោះ។<br>ចំណែកឯទ្វិកនិយម(dualism)វិញ អះអាងថា មនុស្សត្រូវបានបង្កើត ឡើងពីធាតុពីរ គឺកាយ(រូបធាតុ)និងចិត្ត(ស្មារតីឬព្រលឹង) ដែលមិនអាច កាត់ផ្តាច់ពីគ្នាបានទេ។<br>(ពាក្យនេះគេប្រើនៅក្នុងទស្សនវិជ្ជាអំពីចិត្ត) |
| **២- មនសិការ**<br>អ. Conscience<br>បារ. Conscience | ការភ្ញាក់រលឹករបស់មនុស្សដែលជួយឱ្យមនុស្សស្គាល់ត្រូវ ស្គាល់ខុស និង ដឹងថាអ្វីគួរធ្វើអ្វីមិនគួរធ្វើ។ មនសិការត្រូវបានគេជឿថាជាប្រភពមួយក្នុង ចំណោមប្រភពសំខាន់ៗនៃសីលធម៌។<br>ទស្សនវិទូផ្សេងៗបានយល់ខុសគ្នាអំពីមនសិការ ដោយចាត់ទុកមនសិការ ថាជាសមត្ថភាពខាងសីលញាណរបស់មនុស្ស សំឡេងរបស់អាទិទេព សតិផ្ទាល់ខ្លួន និងជាសំឡេងរបស់វិចារណញ្ញាណ។ |



## ៥-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨

ថ្ងៃពុធ ៩កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម បានបន្តប្រជុំ ពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច បានចំនួន០៤ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- រតនាគារជាតិ<br>អ. national treasury<br>បារ. Trésor national | ស្ថាប័នជាតិទទួលបន្ទុកជាបេឡាធិការនិងគណនេយ្យករសាធារណៈ។ |
| ២- គណនេយ្យករ<br>អ. accountant<br>បារ. comptable (N.) | បុគ្គលដែលមានគុណវុឌ្ឍិក្នុងការកត់ត្រានិងការរក្សាបញ្ជីចំណូល ចំណាយ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សវនកម្មនិងវិភាគ គណនី និងការផ្តល់យោបល់លើបញ្ញត្តិពន្ធនានានិងឱកាសវិនិយោគ។ |
| ៣- គណនេយ្យ<br>អ. accounting<br>បារ. comptabilité (f.) | ការកត់ត្រាជាប្រព័ន្ធនិងគ្រប់ជ្រុងជ្រោយអំពីប្រតិបត្តិការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អង្គភាព ឬស្ថាប័នណាមួយ។ |
| ៤- អាជីវករប្តូរប្រាក់<br>អ. money changer<br>បា. | អ្នកប្រកបមុខរបរប្តូរប្រាក់ដែលមានអាជ្ញាបណ្ណ។ |



## ៦-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨

ថ្ងៃអង្គារ ១៥កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ហ៊ាន សុខុម បានបន្តប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការទស្សនវិជ្ជាបាន ចំនួន០៥ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| **១- ញាណ**<br>អ. consciousness<br>បារ. conscience | *សភាពនៃការដឹងខ្លួន ការស្គាល់ ការយល់ ការចេះ និងការដឹងពីអ្វីមួយដែលកំពុងកើតឡើងនៅជុំវិញខ្លួនយើង។* ម្យ៉ាងទៀត ញាណ គឺជាសភាពចិត្ត ដូចជាការឈឺចាប់ វេទនារម្មណ៍ គំនិត និងការយល់ដឹងខាងផ្លូវចិត្តផ្សេងៗទៀត។ |
| **២- សច្ចភាពចាំបាច់**<br>អ. necessary truth<br>បារ. vérité nécessaire | សច្ចភាពធម្មជាតិដែលមានសភាពពិតនៅក្នុងខ្លួនវា។ សច្ចភាពចាំបាច់ ត្រូវតែពិត និងមិនអាចមិនពិតទេ។<br>សច្ចភាពបែបតក្កវិជ្ជា និងគណិតវិទ្យា ជាទូទៅ ត្រូវបានគេចាត់ទុកថាជាគំរូនៃសច្ចភាពចាំបាច់។ ពួកវិចារណញ្ញាណនិយម អះអាងថា សច្ចភាពចាំបាច់ គឺជាសច្ចភាពនៃវិចារណញ្ញាណ និងផ្អែកលើការយល់ឆ្លុះជ្រៅទៅក្នុងទំនាក់ទំនងពិតរវាងហេតុការណ៍នានា។ ចំណែកឯពួកពិសោធនិយមវិញ អះអាងថា ពុទ្ធិស្ដីពីពិភពលោកត្រូវតែផ្អែកលើការយល់ដឹងដោយវិញ្ញាណ។ ដូច្នេះ វាអាចគ្មានសច្ចភាពចាំបាច់ ឬមានសច្ចភាពចាំបាច់ ប៉ុន្តែ វាគ្មានការបញ្ជាក់ផ្ទាល់ពីពិភពពិតទេ។ (ពាក្យនេះគេប្រើនៅក្នុង តក្កវិជ្ជា ពុទ្ធិវិទ្យា អស្តិរូបវិជ្ជា និងទស្សនវិជ្ជាអំពីវិទ្យាសាស្ត្រ) |

| | |
|---|---|
| **១- ភាពចាំបាច់ដាច់ខាត**<br>អ. absolute necessity<br>បារ. nécessité absolue | ភាពចាំបាច់ដែលមាននៅក្នុងខ្លួនរបស់វា ហើយភាពចាំបាច់ដាច់ខាតនេះត្រូវបានហៅផងដែរថា ភាពចាំបាច់ខាងគណិតវិទ្យា ភាពចាំបាច់ខាងអស្តិរូបវិជ្ជា ឬភាពចាំបាច់ខាងតក្កវិជ្ជា។ ភាពចាំបាច់ដាច់ខាតនេះ ផ្ទុយពីភាពចាំបាច់សន្មត។ ភាពចាំបាច់ដាច់ខាតនេះគឺជាករណីសាកលនិងគ្មានលក្ខខណ្ឌ។ សច្ចភាពនៃភាពចាំបាច់ប្រភេទនេះ គឺជាសច្ចភាពនៃវិចារណញ្ញាណ។<br>(ពាក្យនេះគេប្រើនៅក្នុងតក្កវិជ្ជា អស្តិរូបវិជ្ជា និងទស្សនវិជ្ជាអំពីគណិតវិទ្យា) |
| **២- ភាពចាំបាច់សន្មត**<br>អ. Hypothetical necessity<br>បារ. nécessité hypothétique | ភាពចាំបាច់ដែលគេផ្តល់ឱ្យដូចមានអត្ថិភាពក្នុងសង្គម ហើយភាពចាំបាច់សន្មតនេះត្រូវបានហៅផងដែរថា ភាពចាំបាច់ខាងសីលធម៌ ភាពចាំបាច់ខាងវិបាក ឬភាពចាំបាច់ខាងរូបី ។ យោងតាម ឡេបនីស(Leibniz) សភាពរបស់ពិភពលោកបច្ចុប្បន្ន មិនមែនជាភាពចាំបាច់ដាច់ខាតទេ ប៉ុន្តែ វាគ្រាន់តែជាភាពចាំបាច់សន្មតប៉ុណ្ណោះ។ ចំណែកឯទស្សនវិទូផ្សេងៗទៀតបានហៅភាពចាំបាច់សន្មតនេះថា ជាភាពចាំបាច់មិនដាច់ខាត ពីព្រោះវាទាក់ទងទៅនឹងការសន្មតជាមូលដ្ឋានណាមួយ។ |
| **៣- គង្វាលសាស្ត្រ**<br>អ. patristics<br>បារ. Patristique | ការសិក្សាអំពីវណ្ណកម្ម និងជីវិតរបស់គ្រូគង្វាល ឬលោកឪពុកសំខាន់ៗនៃវិហារគ្រិស្តសាសនា ពីសតវត្សរ៍ទី១ដល់ទី៩នៃគ្រិស្តសករាជ។ |